Le Cambodge et la Thaïlande

# ប្រទេសខ្មែរ
# និងប្រទេសថៃឡង់

៦

១



ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ..................
រាជបណ្ឌិត្យសភាកម្ពុជា

# អារម្ភកថា

ដោយខ្ញុំបានទទួលព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់ពីសម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ ខ្ញុំមានកិត្តិយសនឹងរៀបរៀងប្រវត្តិនៃការទាក់ទងរវាងខ្មែរនឹងសៀម "ថៃ" ចាប់ពីបឋមកាលមកដល់បច្ចុប្បន្នកាលនេះ ។

ហេតុដែលបណ្តាលឲ្យព្រះរាជហឫទ័យព្រះបិតាឯករាជ្យជាតិ ទ្រង់សោយអារម្មណ៍រហូតដល់ត្រាស់បង្គាប់ឲ្យខ្ញុំតាក់តែងរឿងនេះ មកពីមានសារពត៌មានប្រទេសថៃ នឹងប្រទេសយួនខាងត្បូង ច្រើនចុះផ្សាយបង្វែង ប្តុបំបាត់សេចក្តីពិតជាញឹកៗ ។ មានសុភាសិតបារាំងសែសមួយថ្លែងថា "គេមិនអាចបង្កើតប្រវត្តិសាស្ត្រមួយថ្មីបានទេ (On ne refait pas l'histoire) តែដោយសារតែសារពត៌មានប្រទេសជិតខាងយើង គេចង់បង្កើតប្រវត្តិសាស្ត្រមួយថ្មីតាមទំនើងចិត្តគេ នេះហើយបានជាខ្ញុំអត់ព្រាមិនរៀបរៀងសេចក្តីពិតជូនមហាជនជ្រាបមិនបាន ។



CITE UNIVERSITAIRE DE PARIS
BIBLIOTHEQUE
MAISON
DU CAMBODGE

ខ្ញុំមិនមានប្រាថ្នានឹងតាក់តែងប្រវត្តិសាស្ត្រនេះឲ្យពិស្តារទេ គ្រាន់តែស្រង់យកគោលយោលទៅតាមសេចក្តីបរិយាយនៃសម្តេចព្រះឧបយុវរាជ ដែលព្រះអង្គទ្រង់បានព្រះរាជនិពន្ធក្នុងរឿងនេះជាភាសាបារាំង នឹងសេចក្តីបរិយាយដែលមានចុះនៅក្នុងទស្សនាវដ្ដី "កម្ពុជវដ្តបច្ចុប្បន្ន", លេខ ៤-៥ ពិសេស ខែមេសានឹងឧសភា គ.ស. ១៩៥៨ ។

ខ្ញុំសូមអរគុណអ្នកឧកញ៉ាមហាមន្ត្រី ញឹក-នូវ នាយកក្រុមព្រះរាជមន្ទីរ ដែលបានជួយរៀបចំសេចក្តីនៃសៀវភៅតូចមួយនេះ ។

ខ្ញុំសូមលើកសៀវភៅប្រវត្តិសាស្ត្រសង្ខេបពីរឿងការទាក់ទងរវាងខ្មែរនឹងសៀមនេះ ថ្វាយសម្តេចព្រះឧបយុវរាជ ជាការតបស្នងសងព្រះគេជព្រះគុណដោយទីគោរព ។

ភ្នំពេញថ្ងៃទី ២៥ ខែមិថុនា គ.ស. ១៩៥៨

1958

ប៉ែន-នុត

Penn-Nouth

ព្រឹទ្ធសមាជិកក្រុមឧត្តមប្រឹក្សានៃព្រះរាជា

# ប្រទេសខ្មែរ និង ប្រទេសថៃឡង់

## ព្រះរាជអាណាចក្រខ្មែរ

### ពីបឋមកាលមកដល់នឹងសតវត្សរ៍ទី ១១

ប្រវត្តិសាស្ត្រនៃប្រទេសខ្មែរចាប់កំណើតតាំងពីដើមគ្រិស្តសករាជ មកទល់នឹង គ.ស. ទី ៦ ។ ប្រទេសដែលមាននាមហៅថា ហ្វូណន (១) ហើយដែលតាំងនៅជាខាងត្បូងប្រទេសខ្មែរបច្ចុប្បន្ននេះ មានព្រំដែនឆ្ងាយទូលាយណាស់ទៅដល់ភាគមួយចំណែកយ៉ាងធំនៃប្រទេសថៃ និងកោះម៉ាឡាយូ ។ តែថាពត៌មានជាគោលនៃរឿងនេះ ក៏បានមកតែពីការនិពន្ធ ដែលមិនសូវជាពិស្តារសព្វគ្រប់របស់អ្នកនិពន្ធប្រវត្តិសាស្ត្រជាតិចិន ។

---

"១" តាមអ្នកប្រាជ្ញខាងសិល្បករជាតិបារាំង ថាពាក្យនេះគឺសំនីរបស់ចិនដែលហៅពាក្យភ្នំ មិនបានច្បាស់តាមពាក្យយើង បានសេចក្ដីថានគរ "ភ្នំ" ។

រជ្ជកាលអង្គនេះក៏មានកំណើតក្នុងរវាងគ.ស. ៨០២ ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ២ ។ ៧៥ ឆ្នាំក្រោយពីនោះមក ក៏ព្រះឥន្ទ្រាវរ្ម័ន ដែលទ្រង់បានកសាងប្រាសាទសិលាជាលើកដំបូងនឹងទំនប់ទឹកធំ ៗ ផងនោះ ព្រះអង្គបានសោយរាជសម្បត្តិលើអាណាចក្រ ដែលមានព្រំដែនពីខេត្តមាត់ជ្រូក "ប៉ូជុក" ទៅទល់នឹងឧបុល "ឧបោន" ។

មានសេចក្ដីនៅលើចម្លាក់សិលាចារឹកមួយ បានបែងអះអាងថា "ការគ្រប់គ្រងប្រទេសនៃព្រះមហាក្សត្រិយ៍អង្គនេះ បីដូចជាកម្រងផ្កាម្លិះមួយដែលពាសពេញលើព្រះកេសនៃព្រះរាជា ប្រទេសចិន ចម្ប៉ា នឹងជ្វា ដែលទ្រង់តែងប្រកបតែដោយការឈ្នះពាន ។ បានសេចក្ដីថា ក្នុងសម័យនោះ មានមហាអំណាច៤តាំងនៅក្នុងទ្វីបអាស៊ីចុងបូពា៌គឺ:

ប្រទេសចិនក្នុងរជ្ជកាល "តាំង" ព្រះរាជអាណាចក្រចម្ប៉ា ដែលមានព្រះរាជធានីមាននាមថា "ឥន្ទ្របុរ:" សព្វថ្ងៃនេះគឺឈ្មោះ "ក្វាងណាម" រាជាណាចក្រមាតរាម "ជ្វា" នឹងស្រីវិជ័យ "ស៊ូម៉ាត្រា" នឹងរាជាណាចក្រខ្មែរ ។


MOGAUNG
YUN-NAN
CHINE
BHAMO
1220
1220
CH'IENG RUNG
PAGAN
HANOI
OMONÉ
CHIENG SENG
LUANG P'RABANG
HAI-NAN
CH'IENG MAI
VIENG-CHAN
SAY-FONG
SAVANKALOK
SUKHOTAI
1285
RANGOUN
UBON
K'ORAT
PIMAI
1350
1890
PRACHIN
BANGKOK
KOH KER
STUNG TRÊNG
BATTAMBANG
ROLUOS
SAMBOR
KOMPONG CHAM
PHNOM PENH
ANGKOR BOREI
BA PHNOM
SAIGON
MER DE CHINE
DÉTROIT DE MALACCA
SINGAPOUR
BORNÉO

ក្នុងរជ្ជកាលព្រះបាទសុរិយវរ្ម័នទី ១ "១០០២–១០៥០" អាណាចក្រខ្មែរ មានព្រំដែនរហូតដល់ភូមិភាគខាងលិច និងខាងត្បូងនៃដែនកូសាំងស៊ីន ឆ្នេរទន្លេមេគង្គ និងឆ្នេរទន្លេមេណាម (សុំមើលផែនទី) ។

អំពីប្រវេសន៍ គឺការហាកហោលប្រទេសនៃជនជាតិថៃមកទល់នឹងសតវត្សរ៍ទី ១១ ហើយគេមិនដែលប្រទះឃើញមាន ចុះនាមជនជាតិថៃក្នុងអក្សរបម្លាក់សិលាចារឹករបស់ខ្មែរម្តងសោះទេ ។ ជនជាតិនេះបានប្រមូលគ្នាជាក្រុមៗ ក្នុងអំណាចស្តេចត្រាញ់មួយអង្គ ៗ ហើយតាំងទីលំនៅក្នុងតំបន់ទិសឧត្តរឆ្ងាយពីប្រទេសខ្មែរ ក្នុងចំណោមដំបន់ជិតយុនណាន់ ទឹងកូមាទឹងក្នុងយុនណាន់នេះឯងផងៗ

ក្នុងសតវត្សរ៍ទី ១២ ទើបតែពើបប្រទះជាលើកដំបូងនូវរូបភាពនៃជនជាតិថៃលើរូបបម្លាក់ថ្មនៃប្រាសាទអង្គរវត្តព្រមទាំងមានសេចក្តីខ្ចះឲ្យនាមថា "ស្យាម" ហើយបញ្ជាក់ថាជាពួកព្រៃ ៗ

រីឯការពិតនោះ គឺតាំងពីដើមសតវត្សរ៍ទី ១២ មកពួកថៃនេះ បានរំកិលពីយុនណាន់ចិតចូលមកទិសខាងត្បូងតែថាជាន់នោះទៀតក៏ពួកនេះលបលួចចូលមកបន្តិចៗក្នុងកំណត់ពេលជាយូរដោយចុះមកតាមដងទន្លេទឹងស្ទឹងៗការដែល

លបលួចចូលមកបែបនេះហើយដែលជាដើមកំណើតនៃការរុកពានទន្ទ្រានលុកលុយជាខ្លាំង ដែលនឹងមនេតមកទៀតៗ

ការរុកពានទន្ទ្រានបែបនេះកើតឡើងជាខ្លាំងក្នុងដើមសតវត្សរ៍ទី ១៣ ដោយសារតែមានការរុកពានទន្ទ្រាននៃពួកម៉ុងគោលដល់ប្រទេសចិន នឹងនយោបាយបង្រួបបង្រួមប្រមូលទឹកដីនៃស្ដេចគុប៊ីឡាយខាន់ ។ ក្នុងរវាងគ្រិស្ដសក-រាជ ១២២០ ទើបមានការប្រឡោមយកទឹកដីពិតៗ ។ ពួកជនជាតិថៃដែលបានចុះមកពីប្រទេសតូចមួយ ក្នុងអំណាចគ្របគ្រងស្ដេចត្រាញ់មួយព្រះអង្គមាននាមថា "ម៉ូគោង" (Mogaung) ស្ថិតនៅទិសខាងជើងភាម៉ូ (Bhamo) នោះ ហើយដែលបានមកប្រឡោមយកមឿងណៃ ក្នុង គ.ស. ១២២៣ អស្សានក្នុង គ.ស. ១២២៩ នឹងជៀងសែន ៗ

ក្នុងពេលដដែលនោះ ពួកថៃដែលភៀសចេញពីប្រទេសដើម ហើយមកតាំងទីលំនៅ នៅសុខោទ័យនោះក៏បះឡើង ។ មានស្ដេចថៃពីរអង្គបានវាយប្រឡោមដណ្ដើមយកវិត្រស្ហួគាលោក ដោយបានបណ្ដេញចៅហ្វាយ

ខែត្រខ្មែរចេញ ហើយតាំងជារាជាណាចក្រមួយឡើង ។ គឺនៅក្នុងគ.ស.១២៨៥នោះហើយ ដែលព្រះចៅរាមកំ-ហែងបានចាកចេញពីខែត្រសុខោទ័យ មកវាយដណ្ដើមយកឆ្នេរទន្លេមេណាមជាភូមិភាគនៃព្រះរាជអាណាចក្រខ្មែរ ។ ចាប់តាំងពីគ.ស. ១៣៥០មក ក៏ជាតិថៃដែលបានឡើងជាម្ចាស់ដីដែលមានព្រំដែនពីហ្លួងព្រះបាងមកទល់នឹងលពបុរី "លវោ" ក្នុងគ.ស. ១៣៥០ ព្រះចៅរាមាធិបតីបានបញ្ចូលខែត្រសុខោទ័យនឹងលពបុរី ហើយតាំងជារាជធានីនៅក្រុងអយុធ្យា ។

រហូតមកដល់សតវត្សរ៍ទី១៥ហើយក៏ខែត្រក្រាត,បស្ចិម "ប្រជិម,, នឹងចន្ទបុរ នៅស្ដិតគង់វង់ជាភូមិភាគព្រះរាជាណាចក្រខ្មែរដែរ ក៏ប៉ុន្តែក្នុងទ័ពថៃចេះតែចូលលុកលុយប្រទេសខ្មែរជាញឹកៗ ហើយបានប្រឡូកវាយយកអង្គរបានដល់ទៅពីរលើក ។ ពេលនោះក៏ព្រះបាទពញាយ៉ាតទ្រង់ចាកចោលព្រះរាជធានីអង្គរ ដែលខ្មាំងបានលុកលុយបានដោយងាយនោះ ហើយក៏ទ្រង់បានមកតាំងព្រះរាជ-

ធានីនៅក្រុងភ្នំពេញវិញ ។ ក្នុងសតវត្សទី ១៥ ព្រះមហា-ក្សត្រិយ៍ខ្មែរគ្រប់ព្រះអង្គ ទ្រង់បានថែរក្សាឲ្យខេត្តនានានៃព្រះរាជអាណាចក្រដែលមានតែពលរដ្ឋជាតិខ្មែរនៅនោះឲ្យគង់វង់នៅទាំងអស់បាន ។ ប៉ុន្តែក្នុងពេលដដែលនោះបំណែកទិសខាងកើត ពួកយួនបានបញ្ចេញមុខមកទៀតហើយតាំងខ្លួនជាសត្រូវពេញទី ។ រហូតមកទល់នឹងពេលដែលបារាំងសែសចូលមកកាន់ប្រទេសយើងនេះ ព្រះរាជាណាចក្រចូលកាន់សម័យប្រវត្តិសាស្ត្រ ដែលត្រូវងបម្បាំងស៊ីសាច់ហុតឈាមកម៉្បាំងមួយទល់នឹង ១០ ប្រយុទ្ធទល់នឹងសត្រូវពីរ គឺសៀម នឹងយួន ដែលជាអ្នកលុកលុយប្រឡាមយកទឹកដី ។

x

x x

## ជនជាតិថៃ នឹងអារ្យធម៌ខ្មែរ

ជនជាតិថៃដែលបានចុះពីទិសខាងជើងមកក្នុងសតវត្សទី ១៣ នោះ នៅខ្សត់ខ្សោយខាងអារ្យធម៌នៅឡើយ មិនទាន់មានតួអង្គជារដ្ឋប្រកបដោយ ឯកប្បនិយម គ្មានអង្គការ

ខាងសង្គមកិច្ច ខាងនយោបាយត្រឹមត្រូវនៅឡើយទេ គឺ ប្រមូលគ្នានៅជាពួក ៗ ក្នុងអំណាចស្ដេចត្រាញ់ ១ អង្គ ៗ ពុំនោះសោតទេមានតែជាក្រុម ៗ ផង ៗ សម័យនោះទៀត ក៏មិនទាន់មានអក្សរជាតិផង ហើយខាងសិល្បៈក៏មិនដែល មានសល់ទុកកេរ្ដិ៍ដំណែលអ្វី ដល់បច្ចុប្បន្ន សម័យនេះសោះ ផង ៗ ក៏ប៉ុន្តែពួកថៃនេះក្រេបរសជាតិវប្បធម៌ដ៏ធំធេងរបស់ ខ្មែរបានដោយងាយណាស់ៗ មានពាក្យអក្សរខ្មែរជាច្រើន បានចូលទៅជាភាសាថៃ ហើយព្រះរាជារាមកំហែង ក៏ បានកែប្រែអក្សរខ្មែរជាអក្សរសាស្ត្រថៃឡើង ៗ ជំនួយនៃ សិល្បសាស្ត្រខ្មែរដល់ជាតិសៀមនេះ ក៏មានទូលំទូលាយ ណាស់ ទោះក្នុងផ្នែកនយោបាយក្ដីក៏របៀបនយោបាយខ្មែរ ដែលប្រកបដោយរស្មីត្រចាំងត្រចះនេះហើយ ដែលជាគំរូ នយោបាយសៀមក្នុងការតាក់តែងរាជាណាចក្រអយុធ្យា ៗ ការជំនួយខាងអារ្យធម៌សម្ភារៈ និងសិល្បៈទៀតក៏មិនមែន ជាថោកថយដែរ ៗ

តែទោះជាជនជាតិថៃដែលមានកំណើត ដោយបាន ក្រេបជញ្ជក់អារ្យធម៌ខ្មែរយ៉ាងធំទូលាយដូច្នេះក្ដី ក៏មិនមាន

ញញើតនឹកដល់គុណបន្តិចបន្តួចសោះឡើយ មានតែពីដួញចិត្តរំលាយបុសគល់អារ្យធម៌នេះក្នុងកម្លុងពេល ៤ សតវត្សរ៍ដែលខ្លួនលុកលុយដែនដីខ្មែរ ។ មានហេតុមួយដែលគួរកត់សំគាល់ជាពន់ពេក គឺថានៅក្នុងសតវត្សរ៍ទី ១៨ និងទី ១៩ ជាតិថៃបានខំប្រឹងបង្ខំឲ្យជាតិខ្មែរប្រតិបត្តិតាមទំនៀមទំលាប់របស់ខ្មែរ ដែលខ្លួនយកទៅក្រឡៃតាមបច្ចេកលក្ខណរបស់ខ្លួន ។

នាបច្ចុប្បន្ននេះសោតទៀត ក៏ថៃមិនមានញញើតនឹងហាមាត់ជានាអះអាងថា ប្រាសាទខ្មែរនានាមានប្រាសាទព្រះវិហារជាដើមនោះជាបេតិកភណ្ឌ គឺសម្បត្តិរួមជាតិខ្មែរនឹងថៃ មានកាលហ៊ានទាំងពោលថា ជាស្នាព្រះហស្តនៃក្សត្រិយ៍ថៃ ដែលកាលសម័យនោះនៅគង់តែដោយជង្គំចម្ងាយច្រើនពាន់គីឡូម៉ែត្រ ទិសខាងជើងនៃអាណាចក្រខ្មែរនៅឡើយ ។

x x

x

# ការលុកលុយរាតត្បាតរបស់សៀមក្នុងសតវត្សទី១៩

ក្នុងពាក់កណ្ដាលដើមនៃសតវត្សទី១៩ នោះមានតែចម្បាំងជាយូររ៉ាំងប្រទេសខ្មែរ ដែលចុះអន់ខ្សោយទៅហើយនោះនឹងប្រទេសជិតខាង ទិសខាងលិចនិងខាងកើត ។ តែទោះបីជាយ៉ាងនោះក៏ដោយ ក៏កងទ័ពខ្មែរដែលត្រូវទប់ទល់ទឹងជំនន់នៃកងទ័ពបរទេស ដែលហូរពោរពាសមកលើផ្ទៃប្រទេសនោះ ក៏នៅតែធ្វើឲ្យកងទ័ពខ្មាំងបរាជ័យទៅបាន ៗ រាជាណាចក្រខ្មែរក៏នៅតែរក្សាសម្បូរណភាពរបស់ខ្លួនបាននៅឡើយ បានចូលកាន់សេចក្ដីទ្រុឌទ្រោមខ្លះ ថយដំហានខ្លះ បោះបង់ចោលក្រុងណាដែលការពារលែងបានខ្លះនោះក៏ពិតមែនហើយ តែមិនសុខចិត្តស្រែកញ៉មឡើយ ។ ក្នុងប្រវត្តិសាស្ត្រមិនសូវមានប្រជារាស្ត្រណាដូចប្រជារាស្ត្រខ្មែរដែលបានរងសេចក្ដីវេទនាចំនួន៧៥ឆ្នាំដូច្នេះទេ ។ ជាញឹកញយព្រះមហាក្សត្រិយ៍ព្រមទាំងព្រះរាជបរិពារត្រូវចាកចេញចោលព្រះរាជធានីដោយខ្មាំងចូលលុក ឯខ្មាំងនោះសោត បើជាយួនមិនមានញរញើតនឹងបំផ្លាញកំទេចអ្វី ៗ

ដែលទើសមុខសោះឡើយ  បើជាសៀមវិញនោះតែងរើបយកពលរដ្ឋធ្វើជាទាសកម្មករ ហើយបណ្តេញគៀងបណ្តាពស្ត្រាំងខែត្រៗ ឲ្យទៅនៅក្នុងអាណាចក្រខ្លួន ។

ទោះជាមានការផង្រ្គោះដូច្នោះក៏ដោយ  ក៏អាណាចក្រខ្មែរនៅគង់វង់មានជីវិតបាន បើជាប្រើគ្រឿងសស្ត្រាវុធមិនបានផលតាមបំណង  ក៏ប្រជាជាតិខ្មែរតែងស្វែងរកលទ្ធផលបានដោយប្រើមធ្យោបាយទូតយ៉ាងថ្លាត ។ ការដែលសៀមនឹងយួនបានហែកហួរដណ្តើមទឹកដីខ្មែរនេះ ក៏ប្រែក្លាយទៅជាការប្រយុទ្ធពេញទំហឹង រវាងជាតិទាំងពីរនេះដោយទាន់ហន់ដែរ ដោយមកពីចំប្រណាំងប្រជែងចង់បានទន្លេ ៤ មុខនឹងទីក្រុងភ្នំពេញតែរៀងខ្លួន ។ ការប្រយុទ្ធរវាងសៀមនឹងយួន ក៏កើតមានឡើងជាច្រើនៗ រីឯខ្មែរដែលបានចូលប្រយុទ្ធជាមួយនឹងពួកខាងនេះខ្លះ ខាងនោះខ្លះផងនោះ ក៏បានទៅជាតុល្យភាពមួយអាចបង្អាកដំណើរ ‘‘មរណ:’’នៃជាតិខ្លួនបាន ។ គឺនៅសម័យនោះហើយដែលបារាំងសែសបានបេញមុខមកកាន់ភូមិភាគអាស៊ីនេះ ។

ដើម្បីឲ្យបានពិស្តារក្នុងរឿង សៀមនឹងយួនប្រឆាំងគ្នាដណ្ដើមប្រលោមយកទឹកដីខ្មែរនេះ ថ្ងៃក្រោយខ្ញុំនឹងប្រែសំរួលជាភាសាជាតិផ្សាយថែមទៀត នូវអត្ថបទដែលព្រះបាទសម្ដេចព្រះ នរោត្តម-សីហនុ ឧបយុវរាជព្រះអង្គទ្រង់ព្រះនិពន្ធជាភាសាបារាំង សម្ដែងពីរាជនិយមខ្មែរ វគ្គទី ៣ ដែលមានចុះផ្សាយក្នុងសារពត៌មាន ឡារ៉េអាលីតេ ចុះថ្ងៃទី ៧ មិថុនា គ.ស. ១៩៥៨ នេះទៀត ។

# អំពីបារាំងសែសចូលមកកាន់ប្រទេសកម្ពុជា

កងកំឡាំងទ័ពបារាំងដែលបានធ្វើសកម្មភាព ក្នុងដែនកូសាំងស៊ីន ក្នុង គ.ស. ១៨៦១ ទើបនឹងវាយយកដែននេះទាំងមូលបាន លើកខេត្តវិញឡុង, ចូវដុក (មាត់ជ្រូក) នឹងហាទៀង (ពាម) ដែលជាអាណាចក្ររបស់ខ្មែរ ហើយដែលគង់នៅក្នុងកណ្ដាប់ដៃយួននៅឡើយ តែខេត្តទាំងបីនេះ ក៏បានបញ្ចូលក្នុងអាណាខេត្តអាណានិគមបារាំងក្នុង គ.ស. ១៨៦៧ ដែរ ។

ក្នុងគ.ស. ១៨៦១ ឧត្តមនាវី សាណែរ បានចាត់បំរើមួយនាក់ឲ្យមកថ្វាយសេចក្តី ព្រះបាទសម្តេចព្រះនរោត្តម ពីបំណងរបស់បារាំងចំពោះដែនកូសាំងស៊ីន ។ ក្នុងពេលសន្ទនាការអ្នកបំរើនោះ បានថ្វាយសេចក្តីព្រះមហាក្សត្រថា សេចក្តីបំណងរបស់លោកឧត្តមនាវីនោះ គឺសុំកុំឲ្យប្រទេសខ្មែរមានជាប់ចំណងស្ពានមេត្រី នឹងជាតិបរទេសណាឡើយ ហើយដរាបណាប្រទេសខ្មែរមិនមានជាប់ចំណង ស្ពានមេត្រីនឹងជាតិបរទេសនានាឡើយ ដរាបនោះបារាំងនឹងនៅជាមិត្រស្និតថេរនឹងខ្មែរបាន "នេះស្រង់ពីសៀវភៅលោកអា-ឡឺក្លែរ" ។

ប៉ុន្តែបារាំងមានបារម្ភភ្លាមគឺសេចក្តីប៉ុនប៉ងរបស់សៀមចំពោះប្រទេសខ្មែរ ។ ដោយហេតុនេះហើយ បានជាក្នុងខែកក្កដា គ.ស. ១៨៦៣ ឧត្តមនាវីឡាក្រង់ឌីយ៉ែរ ជាគូវែរណើរហ្សេណេរាលនៅដែនកូសាំងស៊ីន បានទូលស្នើដល់ព្រះបាទសម្តេចព្រះនរោត្តម សុំឲ្យប្រទេសខ្មែរទៅជាប្រទេសក្នុងការគ្រប់គ្រងប្រទេសបារាំងសែស ។ ព្រះបាទសម្តេចព្រះនរោត្តម ក៏ព្រះអង្គទ្រង់ព្រះរាជតម្រិះយល់ព្រមតាមសេចក្តីស្នើសុំនេះ ។ សន្ធិសញ្ញាស្តីអំពីការគ្រប់គ្រង

ប្រទេសខ្មែរនេះក៏បានទទួលសច្ចាប័នពីប្រទេសបារាំង ក្នុងខែមីនា គ.ស.១៨៦៣។ ចំណែកសៀមក៏មានការក្រេវក្រោធឡើងដែរ ដោយយល់បានថាបំណាងជាឧក្រិដ្ឋរបស់ខ្លួនចំពោះប្រទេសខ្មែរនោះ ត្រូវលាយ សាបសូន្យដូចអំបិលត្រូវទឹក ។

តែជាការអកុសលមួយ ក្នុងពេលដែលប្រទេសបារាំងចង់សម្រេចបញ្ជាក់លក្ខខ័ណ្ឌឲ្យច្បាស់លាស់ពីព្រំប្រទល់ដែនខ្មែរ ព្រោះបារាំងច្រើនតែចាញ់បោកមន្ត្រីយួន និងរដ្ឋាភិបាលសៀម ហើយជាពិសេសទៅទៀត នាំឲ្យខូចប្រយោជន៍ដល់ជនជាតិដែលនៅក្នុងអាណាព្យាបាលខ្លួន គឺខ្មែរយើងនេះជាច្រើន ។

ត្រង់នេះហើយ ដែលត្រូវឲ្យកត់សំគាល់បានជាពិសេសថា ទោះពីអតីតកាលក្តី ក្នុងបច្ចុប្បន្នកាលនេះក្តី ក៏សៀមតែងតែអះអាង ក្លែងបំពានដល់សិទ្ធិដែលខ្លួនគ្មានដល់បន្តិចបន្តួចសោះឡើយ។

ដោយមកពីការបំកាន់នេះហើយ បានជានាំប្រទេសបារាំងឲ្យធ្វើសន្ធិសញ្ញាអកុសលឧត្យាទមួយនាគ.ស.១៨៦៧

ហើយមកដល់បច្ចុប្បន្ននេះទៀត ក៏កំសួលនៃការទតព្រាតនេះ បណ្ដាលឲ្យមហាអំណាចខ្លះ យកត្រដៀកត្រដងត្រាប់ស្ដាប់ នូវការប្រឡោមរំលោភរបស់សៀមចំពោះរឿងព្រះវិហារ ។

សន្ធិសញ្ញាបារាំង-សៀមនាគ.ស.១៨៦៧ក្នុងជំពូកនេះ យើងគ្រាន់តែស្រង់យកសេចក្ដីដែលហ្ស.ម៉ូរ៉ា (*J. Moura*) លោកបានសរសេរទុកក្នុងគ.ស.១៨០៣ ដូចតទៅនេះ ៖

សន្ធិសញ្ញារវាងបារាំងសៀម ក្រោយដែលបានទទួលសច្ចាប័នពីរដ្ឋាភិបាលហើយ ក៏បញ្ជូនត្រឡប់ដល់ក្រុងព្រៃនគរវិញនៅក្នុងខែកក្កដា គ.ស. ១៨៦៧ ដើម្បីជាសំ-ណាងនៃអំណាចអធិរាជដែលសៀមអះអាងដោយក្លែងថាខ្លួនមានមកលើប្រទេសខ្មែរនេះ បារាំងក៏បានលើកឲ្យទៅសៀម នូវខែត្របាត់ដំបងនិងអង្គរ គឺជាខែត្រដែលសៀមប្រឡោមយកដោយឥតច្បាប់តាំងតែពី គ.ស. ១៧៩៤ ។ សេចក្ដីសម្រេចបែបនេះគឺប្រទេសបារាំងបានធ្វើតាមសេចក្ដីស្នើសុំរបស់លោកកុងស៊ុលបារាំងប្រចាំបាងកក ដែលទើបនឹងចូលធ្វើរាជការទូតថ្មីៗ ហើយចង់បញ្ចេញបុទ្ធឲ្យឃើញជាក់

ស្តែងថាខ្លួនមានជ័យជំនះៗព្រះរាជាដែលត្រូវរងគ្រោះដោយ
គេដកហូតយកអាណាខេត្រ ដោយមិនបានដឹងព្រះអង្គនោះ
ក៏ទ្រង់បានតវ៉ាដែរ ៗ រីឯលោកគូវែរណឺរកូសាំងស៊ីន ដែល
លោកគួរនឹងជូនយោបល់គាប់កើតនោះ ក៏រាជការបារាំង
មិនបានសួរនាំដល់លោកសោះដែរក្នុងរឿងនេះ ហើយតាម
ដែលដឹងមកនោះថា លោកមានភ្ញាក់ពីសេចក្តីសម្រេចនេះ
ដែរ ហើយមានទោមនស្សទាស់តូចចិត្តខ្លះផង ៗ រដ្ឋា-
ភិបាលបារាំងមិនបានដឹងខ្លួនថា អំពើបែបនេះជាពលិកម្ម
អកុសលមួយដ៏ក្រៃលែង បើជាយកប្រៀបធៀបនឹងការ
ដែលសុំឲ្យសៀមបោះបង់ចោល នូវសេចក្តីអះអាងទាំងឡាយ
លើប្រទេសខ្មែរនោះព្រោះឫទ្ធិអំណាច ដែលខ្លួនអួតអាងថា
មានមកលើខ្មែរនោះក្តី រូបខ្លួនក្តី ក៏សាបរលាបចេញពីដែន
ខ្មែរជាយូរណាស់ហើយ តាំងតែពីបារាំងបានចេញមុខមក
តទល់ម្ល៉េះ ៗ

ក្នុងវដ្ឋកាលព្រះអង្គទាំងមូលព្រះបាទសម្តេចព្រះនរោត្តម
ទី ១ ព្រះអង្គមិនដែលឈប់ឈរស្វែងទារយកខេត្រទាំង

ពីរនោះមកវិញសោះ ព្រោះខេត្តទាំងពីរនេះមានសុទ្ធតែជនជាតិខ្មែរនៅ រីឯខេត្តមួយទៀតនោះសោតមានប្រាសាទអង្គរវត្តសៀម គ្មានសិទ្ធិអ្វីទៅលើដល់តិចតួចសោះឡើយ ។

លុះតែដល់មកឆ្នាំ ១៩០៤ ទើបបានបាត់ដំបងនឹងអង្គរបានវិលត្រឡប់មកជាទឹក-ដីរបស់ខ្មែរវិញ ។

x x x

## សន្ធិសញ្ញាប៉ុះប្ញៃ ២៣ មីនា គ.ស. ១៩០៧

នៅថ្ងៃ ១៣ កុម្ភៈ ១៩០៤ បារាំងនឹងសៀមបានធ្វើអនុសញ្ញា១តាមសេចក្ដីអនុញ្ញាតនោះសៀមព្រមទទួលស្គាល់នូវអំណាចរបស់ខ្មែរលើខេត្តទន្លេរពៅ-មូលព្រៃនឹងកោះកុង ។ រីឯសន្ធិសញ្ញា ឆ្នាំ១៩០៧ សម្រេចត្រូវឲ្យបានខេត្តបាត់ដំបងនឹងអង្គរមកប្រទេសខ្មែរវិញ ។

គឺនៅពេលនោះហើយ ដែលភូមិភាគរបស់ខ្មែរមួយចំណែកយ៉ាងធំ ដែលមានតែជនជាតិខ្មែរនៅនោះត្រូវបានវិលត្រឡប់មកមាតុប្រទេសយើងវិញ ។

សមាជិកក្រុមជំនុំបារាំងបានកត់សំគាល់ថា សៀមមានធនុះល្អដែរ ព្រមទាំងមានបំណងសម្រុះសម្រួលពិត ៗ ផង មានក្នុងការបោះគោលព្រំដែនជាដើម ។ គួរឲ្យជឿបានថា សៀមបានលះបង់នូវការរាយមាយចង់ប្រឡូមយកទឹក-ដី ខ្មែរទៀតហើយ ។ ឯសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃ ១៤ កុម្ភៈ ១៩២៥ ក៏បានបញ្ជាក់សម្រេចជាដាច់ខាតពីព្រំប្រទល់ខ្មែរ-សៀម ដែលមានចែងទុកក្នុងសន្ធិសញ្ញា ១៩០៤ និង ១៩០៧ ។

## គំនិតបក្រពត្តិនិយមសៀម បានចាប់កំណើតឡើងវិញទៀតហើយ

មានសន្ធិសញ្ញាថ្មីមួយទៀតរវាងបារាំង-សៀម ចុះថ្ងៃ ៧ធ្នូ គ.ស.១៩៣៧ បានសម្រេចបញ្ជាក់ម្តងជាថ្មីទៀតនូវព្រំប្រទល់ដែនខ្មែរ-សៀម តែពេលនោះបរិយាកាសបានប្រែប្រួល ដោយគណបក្សសឹកដែលកាន់តែមានកម្លាំងនោះ បានសំដែងឲ្យឃើញថា ខ្លួនមានសេចក្តីស្ងប់ស្ងៀងផល់

ប្រទេសអាល្លឺម៉ាញក្នុងអំណាចហ៊ីត្លែរ និងប្រទេសជប៉ុន ប្រកបដោយរបៀបកម្លាំងសឹក ។

រដ្ឋមន្ត្រីក្រសួងការពារប្រទេស មិនមានលាក់នូវដំណើរនយោបាយថ្មីសៀមឡើយ ហើយបានផ្សាយតាមវិទ្យុនូវប្រកាសដូចនេះ "ជាតិនានាត្រូវតែចាំពេលណាដែលខ្លួនមានដុះបង្កួម នឹងដុះក្រចកឲ្យវែងសិនសឹមកុំហ៊ុកធ្វើសកម្មតាមបែបណាក៏ដោយ" តើសំដីនេះជាពាក្យអំនួតឬ? មិនមែនទេព្រោះព្រឹត្តិការណ៍នៃឆ្នាំ ១៩៤០-១៩៤១ បានមកបញ្ជាក់ជូនតាងថាសំដីនេះជាសំដីពិតរបស់សៀម ។ យើងមិនអាចនឹងឆ្ងល់ពីសកម្មភាពប្រឡោមទាមទារយកទឹក - ដីរបស់ខ្មែរដែលសៀមបានបង្វិលឲ្យមកវិញនោះទេ ។ នៅពេលនោះទៀតក្រសួងផែនទីសឹកសៀម បានបែកនូវផែនទីក្លែងក្លាយតាមទំនើងចិត្តខ្លួន ដែលមានព្រំដែនប្រទេសតាំងពីកាល ១៥០ ឆ្នាំមុននេះ គឺបញ្ចូលឆ្នេរទន្លេមេគង្គកណ្តាល តុងកឹងលើ ប្រទេសអណ្ណាមភាគខាងជើង និងដែនខ្មែរទាំងមូលជាអាណាចក្រខ្លួន ។

# ចម្បាំងបារាំង-សៀម

## នាឆ្នាំ ១៩៤០ - ១៩៤១

ក្នុងឆ្នាំ ១៩៤០ ក្រោយដែលបារាំងបានចុះបរាជ័យខាងទ្វីបអឺរ៉ុប ក៏សៀមតាំងបញ្ចេញបញ្ចេញគំនិតប៉ុនប៉ងនឹងរំលោភលើដែនដីខ្មែរនឹងលាវផែរ ហើយបានបញ្ចេញអាការៈនេះយ៉ាងសាហាវ ៗ មានកប៉ាល់ជប៉ុនជាច្រើនបានដឹកសម្ភារៈសឹកជាច្រើនមកដាក់ក្រុងបាងកក មានដឹកទាំងគ្រឿងសស្ត្រាវុធអាមេរិកាំងថែមមកលើនោះទៀតផង ៗ

ចុងខែកញ្ញា ១៩៤០ សៀមលែងលាក់បំបាំងនូវគំនិតអាក្រក់ខ្លួនហើយ ហើយចាប់តាំងបង្កបង្កើតរឿងតាមជងទន្លេមេគង្គជាញឹកញយ ៗ ដើមខែធ្នូ សភាពចម្បាំងចាប់តាំងមានកើតឡើងរវាងឥណ្ឌូចិននឹងសៀមហើយ ៗ

ខាងដើមគោក ការប្រយុទ្ធមិនសូវជាមានធំដុំទេ ព្រោះកងកម្លាំងដែលយកមកតទល់មានយ៉ាងច្រើនមិនហួសពី ៥ កងនៃវរសេនាធំទេ ៗ ពួកអ្នកសង្កេតការណ៍ទាំងឡាយបានមូលមាត់គ្នាថា ប្រជាពលរដ្ឋសៀមច្រើនមិនសូវត្រេកត្រអាល

ពេញចិត្តនឹងចម្បាំងនេះសោះទេ រីឯខាងជើងទឹកវិញក៏មាន
តែការប្រយុទ្ធគ្នានៅកោះឆាំង នៅថ្ងៃ ១៧ មករា ១៩៤១ ។
នៅពេលប្រយុទ្ធនោះក្នុងរវាងប៉ុន្មានម៉ោង ក៏នាវាចម្បាំង
សៀមកើតឆាយ បានត្រូវគ្រាប់លិចបាត់បង់ទៅក្នុងបាត
សមុទ្រជាច្រើន ដោយសារស្នាដៃកងកម្លាំងជើងទឹកបារាំង
ដែលពេលនោះ ក៏មិនសូវជាមានសម្បូណ៌គ្រប់គ្រាន់ប៉ុន្មាន
ដែរ ។ ក្រោយដែលបារាំងមានជ័យជំនះយ៉ាងអស្ចារ្យនេះ
ក៏មានការគាប់ជួនមួយប្លែកណាស់ដែរ ។ រដ្ឋាភិបាលជប៉ុន
ក្រុងតូក្យូ បានបង្ខំដោយឱសានុវាទឲ្យស្ទុះចម្បាំងនេះ
ហើយបង្ខំឲ្យទទួលយកប្រទេសខ្លួនជាអាជ្ញាកណ្ដាល ក្នុង
ការវិវាទនេះ ‹‹សំដីរបស់លោកដឹគូ›› ។ ការបញ្ឈប់
ចម្បាំងក៏ទុកជាដាច់ស្រេចពីថ្ងៃ ២៨ មករា រីឯការជំនុំរក
សន្តិភាពវិញក៏ត្រូវចាប់ធ្វើពីថ្ងៃ ៧ កុម្ភៈ ឯក្រុងតូក្យូ ។

ឧត្ដមនាវីដឹគូ ជាអតីតគូវែរណើរយេរណេរ៉ាលឥណ្ឌូ
ចិនបានពោលដូចតទៅនេះចំពោះរឿងសន្ធិសញ្ញានោះ:

‹‹ក្រោយដែលបានជជែកពិភាក្សាគ្នាជាយូរ ដោយ
ម៉ឺងម៉ាត់នោះ អ្នកបរបាខាងយើងត្រូវតែទទួលក្នុងថ្ងៃ ១១-

មីនា១៩៤១តាមសេចក្ដីសម្រុះសម្រួលដែលធ្វើលុះទៅតាមអំពើចិត្តជប៉ុន ហើយដែលនាំឲ្យខូចខាតប្រយោជន៍ជាខ្លាំងគឺធ្វើបំពានគ្មានតាមលំនាំនៃផែនទីបំប៉ាំងសោះឡើយ កាត់យកពីដែនឥណ្ឌូចិន នូវភូមិតាមទឹកដីលាវពីរដុំខាងត្រើយស្ដាំទន្លេមេគង្គព្រមទាំងខេត្តបាត់ដំបងទាំងមូលនឹងចំនួនដី១ភាគមានរង្វង់ព្រំដែនក្នុងដងរែក នឹងខ្សែបន្ទាត់ទឹបកំរិត ១៥ "សុំមើលផែនទី" ។

សន្ធិសញ្ញាសន្តិភាពក៏បានចុះហត្ថលេខា នៅថ្ងៃ៩ ឧសភា ១៩៤១ តែនៅក្នុងសន្ធិសញ្ញានោះរដ្ឋាភិបាលវិស៊ី ក្នុងនាមប្រទេសបារាំង បានសម្ដែងដោយជាក់ច្បាស់នូវថបនីយ (réserve) ព្រោះមានសេចក្ដីរំណេកយោរយៅជាខ្លាំងលើប្រទេសបារាំង ៗ ថ្ងៃនេះទៅជាអ្នកគ្រប់គ្រងប្រទេសថៃមកពោលសំអាងថា ក្នុងខណៈធ្វើសន្ធិសញ្ញានោះប្រទេសសៀមបានលុះដោយសេចក្ដីភ័យញាប់ញ័រ ដោយមានការបង្ខិតក្នុងផ្លូវចិត្ត រីឯសន្ធិសញ្ញាដែលល័ក្ខខណ្ឌព្រំដែនខ្មែរសៀមនោះសោតក៏ត្រូវកត់សំគាល់ថា បានធ្វើនៅពេលសន្តិភាពទេតើ ម្ដេចក៏មកពោលថា ធ្វើក្នុងអំណាច


THAILANDE
LAOS
VIET NAM
Preah Vihear
Sisophon
Angkor
Siem Reap
Stung Treng
Battambang
TONLE SAP
MÉKONG
Kp. Thom
Kratié
Pursat
Kp. Chhnang
Kompong Cham
PHNOM PENH
Kompong Speu
Prey Veng
Koh Kong
GOLFE
DE
THAILANDE
Takéo
Svay Rieng
Kampot
MÉKONG
Légende
Frontière en 1941-1946 après les annexions thailandaises
Echelle 1/2.000.000

ភយាគតិទៅវិញ ? លោកឧត្តមនាវីជីគូបានបន្ទុះដៀលត្មះអំពើបំពានបំពារនាឆ្នាំ ១៩៤០ របស់សៀមដែលអាក្រក់ក្រៃលែងនេះ សមតាមអំពើលាមកដូចតទៅ ''ប្រវត្តិសាស្ត្រមុខជានឹងកត់សំគាល់មិនលែងនូវអនុស្សាវរីយ៍ នៃការបំពានបំពាររុករានទន្រ្ទានដោយគ្មានការនាំអាទិ បង្កបង្កើតរឿងជាមុនពីគូសត្រូវម្ខាងនោះសោះឡើយ ហើយមុខជានឹងទុកអំពើរំលោភនេះជាតួយ៉ាង ១ ក្នុងអំពើក្បត់នៃជនជាតិខ្លះ ។ ក៏ប៉ុន្តែគួរយើងឆ្ងល់បានទេ ហេតុអ្វីក៏ប្រទេសថៃសុខចិត្តប្រព្រឹត្តបទឧក្រិដ្ឋបែបនេះ ? នៅក្នុងសាកលលោកនេះមានប្រទេសខ្លះដែលថ្ងៃណា១គង់នឹងទទួល ទណ្ឌកម្មតាមយថាហេតុដែលខ្លួនបានប្រព្រឹត្ត ហាក់ដូចជាត្រូវតែចាំទទួលកម្មវិបាកសម្រាប់តែប្រព្រឹត្តអំពើយង់ឃ្នងឬឃោរកម្មឃោរឃៅគ្រប់ៗ ពេលដែលមានកើតកលិយុគ ។

មុខការបែបពោលមកហើយនេះគឺសមប្រកបទៅតាមអគតិប្រវត្តិសាស្ត្រនៃប្រទេសនោះ ហើយបញ្ចេញព្យួរស្មើស្មោកគ្រោកដែលមានលាក់ទុកក្នុងចិត្ត នៃជនជាតិប្រទេសនោះ ។

# សន្ធិសញ្ញាក្រុងវ៉ាស៊ីនតុន ឆ្នាំ ១៩៤៦

ប្រទេសថៃដោយបានកាន់ជើងមូលគំនិត នឹងមហាអំណាច ៣ មុម (axe) ក្នុងឱកាសមហាសង្គ្រាមពិភពលោកលើកក្រោយនេះ ត្រូវទទួលបង្គាប់តាមសន្ធិសញ្ញាវ៉ាស៊ីនតុនឲ្យប្រគល់ដី ដែលខ្លួនប្រឡោមយកទាំងកម្រោលទាំងប៉ុន្មានទៅប្រទេសដើមវិញ ។

ការចរចាក្នុងរឿងនេះបានធ្វើជាយូរអស់រយៈពេល ១ ឆ្នាំ ក្នុងឱកាសចរចាត្រូវឲ្យកត់សំគាល់បានថា ពួកប្រទេសអង់គ្លូ-ស័ក្សុង (Anglo-Saxon) មានអង់គ្លេសជាដើម លុះបានគាប់ចិត្តដោយសារបានទទួលស្ថានភាពចាស់ដដែលលើដែនមល្លយូវិញនោះ (Malaisie) ក៏បញ្ចេញអាការៈព្រងើយកន្តើយចំពោះរឿងទឹកដី ដែលត្រូវបញ្ចូលមកអាណាចក្រខ្មែរនឹងលាវឲ្យបានសុចរិតយុត្តិធម៌ ។ ក៏ប៉ុន្តែប្រទេសថៃ សុខចិត្តព្រមទទួលវិលមកប្រតិបត្តិការតាមសន្ធិសញ្ញានាឆ្នាំ ១៩៣៧ ដែលមានបញ្ជាក់ថា “ការទាក់ទងតាមទូតត្រូវឲ្យមានឡើងវិញ រីឯការប្រស្រ័យទាក់ទង

វេចងប្រទេសទាំងពីរ ត្រូវប្រតិបត្តិទៅតាមសន្ធិសញ្ញា ឆ្នាំ ១៩៣៧ " ។

កងទ័ពព្រមទាំងរាជការបារាំងនឹងខ្មែរ ក៏បានវិលចូលទៅកាន់បាត់ដំបងវិញ ក្នុងកណ្ដាលបំណោមប្រជារាស្ត្រ ដែលបានបញ្ចេញសេចក្ដីអបអរសាទរជាពន្លឹក ។ តែបើពោលដោយពិតទៅក៏ឃើញថា ក្នុងកំឡុង ៥ ឆ្នាំដែលខេត្តបាត់ដំបងនៅក្នុងកណ្ដាប់ដៃសៀមនោះ រាជការថៃច្រើនតែសង្កត់សង្កិនឲ្យខ្មែរប្រតិបត្តិតាមទាំងក្រៀមក្រំ នូវបញ្ញត្តិនានា ដែលដឹកនាំប្រជារាស្ត្រឲ្យបានចូលកាន់ទំនៀមទំលាប់សៀមសុទ្ធៗ ជាជាងការសង្កត់សង្កិនបង្ខិតបង្ខំនៅវិញៗ បើពោលពីខាងសេដ្ឋកិច្ចវិញ ការដែលសៀមប្រលោមយកខេត្តបាត់ដំបងនេះ គឺបានផលត្រង់បានស្រែចំណានចំនួនទំហំ ១៨៣.០០០ ហិតា បានទីប្រជុំជន ១ ដែលជាទីក្រុងលេខ ២ របស់ប្រទេសខ្មែរនឹងខេត្ត ១ ដែលមានសម្ភារៈគ្រាស់ក្រៃលជាងខេត្តនានាឯទៀត ។

ខេត្តបាត់ដំបងនេះ គ្មានបានទទួលសេចក្ដីចំរើនអ្វីសោះក្នុងពេលដែលនៅក្នុងកណ្ដាប់ដៃសៀម លុះបានវិល

ចូលមកកាន់មាតុប្រទេសវិញកាលណា ក៏ចាប់ប្រឹងប្រែងបំពេញការងារក្រោម ហើយនៅបច្ចុប្បន្ននេះ ខែត្របាត់ដំបងក៏បានទៅជាខែត្ររុងរឿងសម្បូណ៌សប្បាយមួយ របស់ព្រះរាជអាណាចក្រខ្មែរ ១ ទៀតត្រូវឲ្យកត់សំគាល់ថាខែត្រនេះហើយ ដែលបានហៅហាមដោយម៉ឺងម៉ាត់ សម្តេចព្រះនរោត្តម-សីហនុ ឧបយុវរាជ ក្នុងឱកាសដែលព្រះអង្គទ្រង់បំពេញព្រះរាជបេសកកម្ម ទាមទារឯករាជ្យបរិបូណ៌បូជាប្រទេស ហើយក្នុងបច្ចុប្បន្នកាលនេះទៀតក៏បានគាំពារសង្គមរាស្ត្រនិយមដោយពេញទំហឹង ។

អាកប្បកិរិយាទាំងនេះហើយ ដែលអាចនឹងបានជាសេចក្តីបដិសេធនៃការអះអាងរបស់ថៃថា ខែត្របាត់ដំបងនឹងសៀមរាបនេះ បានបង្ខំដកហូតយកពីប្រទេសថៃដំនះបំពានបំពារលើធន្ទះជនជាតិថៃ ។

## អសុទ្ធចិត្តរបស់ថៃ

ប៉ុន្មានសប្តាហ៍ ក្រោយដែលជប៉ុនចុះបរាជ័យមកហើយសៀមក៏អស់សង្ឃឹមពីមហាអំណាច ធ្វើជាឧបការីក្នុងការ

ដឹកនាំឲ្យមានសហវឌ្ឍនភាពដែលមានជប៉ុនជាមេក្លោងនោះ ក៏ជនជាតិថៃចេះតែប្រែគំនិតពត់បែរទៅកាន់ស្ថានការថ្មីដោយ ជ័យជំនះរបស់មហាអំណាចបស្ចិមប្រទេស ។

ក្នុងប្រវត្តិសាស្ត្រនៃមហាសង្គ្រាមលោកលើកទីពីរនេះ មានការមួយប្លែកអស្ចារ្យណាស់គឺពួកអង់គ្លូស័ក្សុង (*Anglo saxon*) សុខចិត្តទុកគណៈបក្សសឹកដែលកាន់ការមកតាំងពីឆ្នាំ ១៩៣៧ ហើយដែលជាសម្ពន្ធមិត្រនឹងជប៉ុននោះ ឲ្យនៅកាន់អំណាចរដ្ឋាភិបាលតទៅទៀត ។ ពួកនេះហើយដែលបានប្រឡាមប្លន់ដណ្តើមយកខេត្តបាត់ដំបង និងសៀមរាបអំពីខ្មែរនឹងភូមិភាគជាច្រើនអន្លើពីប្រទេសមលាយូ ដែលនៅក្នុងអំណាចអង់គ្លេស ទោះបីគណៈបក្សសឹកនោះបានសន្យាធានាអះអាងដូចម្ដេចក្ដី ក៏គំនិតគេចំពោះមកលើប្រទេសខ្មែរវិញមិនមានប្រែប្រួលផ្លាស់ប្តូរសោះឡើយ ។ ពេលនេះទៀតក៏យើងបានទទួលតឹកតាងនៃគំនិតនេះជាថ្មីម្ដងទៀតហើយ ។

កាលនាឆ្នាំ ១៩៤០-៤១ សៀមបានពឹងផ្អែកទៅលើអំណាចស្តុកស្តម្ភប្រទេសជប៉ុន ដើម្បីបំពេញសេចក្ដី

ស្រែកឃ្លានក្នុងការប្រឡោមទឹក-ដី ។ នយោបាយបែប នេះក៏មិនបានសម្រេចតាមបំណង ទើប ១០ ឆ្នាំក្រោយមក សៀម ក៏ប្រើឧបាយទុច្ចរិតប្លែកៗទៀត ដោយពឹងផ្អែកក្នុង បច្ចុប្បន្ននេះទៅលើអង្គការ សេ-អា-តូ (séato) យកមកធ្វើជា រនាំងបាំងមុខ ។ ការចាក់ដោតរិះគន់នៃសារពត៌មានបាងកក ក៏សុទ្ធតែ ជាហេតុ ដើម្បី បង្អើលពួកអង់គ្លូ-ស័ក្សុងផង ( *Anglo-saxon*) ដោះសាអំពើនានា ហើយខំពន្យល់ ថាអំពើទុច្ចរិតនៃខ្លួននេះ គឺជាអំពើជំនួយក្នុងការប្រយុទ្ធទប់ ទល់នឹងលទ្ធិកុម្មុយនិស្តទៅវិញទេ ។ គេខំប្រឹឱតរឿងបង្ហាញ ថាប្រទេសខ្មែរនេះ សព្វថ្ងៃកំពុងពុលនឹងពិសនយោបាយ អព្យាក្រិត ពុំនោះសោតទៅបែរជាចោទថាខ្មែរចង់ទៅ ដណ្តើមយកព្រះវិហារវិញដោយប្រើកម្លាំងសឹក ដោយ អាងលើប្រទេសចិនប្រជាមានិត្ត ។ ការចោទក្លែងតាំង នេះគួរឲ្យអស់សំណើចពន់ពេកណាស់ ក៏ពិតហើយ ក៏ ប៉ុន្តែ គប្បីតែពួកបស្ចិមប្រទេសពិចារណាឲ្យវែងឆ្ងាយផង ហើយយល់ជាច្រើនលើកច្រើនគ្រាមកហើយ បំណងចក្រ ពត្តិនិយមរបស់សៀម និងរបស់យួននៅក្រោមការឧបត្ថម្ភ

ខ្លួន ច្រើនតែមានដំណើរប្រាកដប្លែកពីបំណងទប់ទល់នឹងកុម្មុយនិស្តដូចខ្លួនជឿនោះ ៗ មហាអំណាចបស្ចិមប្រទេសដែលជាមិត្រនឹងខ្មែរហើយដែលសំគាល់បានថា នយោបាយអព្យាក្រិតយើងនេះពិតជាបរិសុទ្ធមែន នោះតើនឹងយល់បានទេ ពីកិរិយាដែលគេលបលួចប្រព្រឹត្តមិនឲ្យខ្លួនដឹងនោះ ដំបូន្មាននៃប្រវត្តិសាស្ត្រថ្មី ៗ នេះតើភ្លេចបាត់ទៅហើយឬ ?

## ឥរិយាបថចំពោះសន្ធិសញ្ញានានា

យើងទើបនឹងបានពណ៌នាពីសាវតារ នៃសន្ធិសញ្ញានានារវាងប្រទេសបារាំង ដែលទទួលគ្រប់គ្រងប្រយោជន៍ប្រទេសខ្មែរនឹងប្រទេសថៃ មានត្រង់ចេតនារម្មណ៍នៃសន្ធិសញ្ញានេះជាដើម ៗ

អើ! ថ្ងៃនេះទៅជាមជ្ឈដ្ឋានជាផ្លូវការថៃទាំងឡាយពោលថា "សន្ធិសញ្ញានោះគ្មានវិស្សមភាព" ដោយចុះហត្ថលេខាក្នុងអំណាចភយាគតិ ៗ ព្រះអង្គម្ចាស់វ៉ាន់បានឆ្លើយនឹងសំនួរនឹងសារពត៌មាន ១ ដូចតទៅនេះ "សន្ធិ

សញ្ញាទាំងឡាយនេះ សុទ្ធតែជាបញ្ហាដែលមិនទាន់ដោះស្រាយ កាលដែលឥណ្ឌូចិននៅក្នុងអំណាចបារាំងសែសនៅឡើយ ។ សន្ធិសញ្ញាទាំងនេះក៏ប្រទេសបារាំងបង្ខំឲ្យចុះហត្ថលេខាក្នុងពេលអាណានិគមនិយមបារាំង,, ។

តែជាហេតុអ្វីក៏គេពុំបានពោលពី "សន្ធិសញ្ញាខ្វះវិស្រមភាព" មួយទៀតផង គឺសន្ធិសញ្ញាវ៉ាស៊ិនតុន ឆ្នាំ ១៩៤៦ ដែលសម្រេចប្រគល់មកឲ្យប្រទេសជិតខាងវិញនូវទឹក-ដី ដែលសៀមប្លន់ដណ្ដើមយក ដែលមានជប៉ុនជួយផងនោះ ។ ការដែលទាមទារបែបនេះពិតមែនជាសៀមមិនហ៊ានស្រែកហ៊ោកញ្ជ្រៀវ ក៏មុខជាផ្ដួចផ្ដើមដុះក្នុងដួងចិត្តរបស់អ្នកគ្រប់គ្រងប្រទេសថៃជាច្រើន សារពត៌មានសៀមបានចោលពាក្យបោះសម្លេង ហើយក្នុងគ្រាដែលហៅឈ្មោះស្រុកខ្មែរតាមសំដីសៀម ឬក៏ធ្វើពើរាប់ខែត្រខ្មែរបញ្ចូលជាទឹកដីសៀម ។

## ការទាមទារទឹកដីដែលថៃបានធ្វើ

ពេលនេះសៀមហ៊ានទាមទារច្បាស់តែព្រះវិហារទេ ប្រហែលជាចាំមានឱកាសល្អ ទើបពង្រីកការទាមទារនេះ

ឲ្យបានក្រាស់ក្រែលទៅទៀត ចំណែកកោះកុងវិញទើបតែហាមាត់តាមតារដោយអឹមអៀមនៅឡើយទេ ។

## ព្រះវិហារ

ក្នុងទស្សនាវដ្តីកម្ពុជរដ្ឋបច្ចុប្បន្នលេខ១ដែលបានចេញកន្លងមក យើងបានពណ៌នាពីព្រះវិហារខាងទិដ្ឋភាពប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ ។ នៅក្នុងទស្សនាវដ្តីលេខ៤-៥ ដែលចេញក្នុងបច្ចុប្បន្ននេះទៀត ក៏ឯកឧត្តម សម-សារី បានថ្លែងដោយច្បាស់លាស់អំពីទិដ្ឋភាពខាងអង្គច្បាប់ ។

តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកសេនាទាហានសៀមនៅតែកាន់កាប់ប្រាសាទព្រះវិហារគ្មានព្រឺ ប្រហែលជាដេកទន្ទឹងចាំពេលណា ទេវតាជួយឲ្យបានឡើងជាម្ចាស់ប្រាសាទនោះពេញទីជាស្ថាពរទេដឹង ?

រឿងនេះ គួរឲ្យឆ្ងល់ពន់ពេកណាស់ ថាហេតុអ្វីបានជាសៀមទទូចតាមតារយកព្រះវិហារបំពានលើច្បាប់ដូច្នេះៗ

បើនិយាយពីខាងនយោបាយ គឺចង់បញ្ចេញឲ្យឃើញថាប្រទេសថៃ មានរិទ្ធអំណាចនិងឥទ្ធិពលខាងការប៉ុនប៉ងពត-

ត្រាតដូចដើមវិញហើយ ហើយប្រាថ្នាមាំថានឹងបំពេញមុខ
ងារជាប្រទេសមេក្លោងក្នុងទ្វីបអាស៊ីទិសអគ្នេយ៍ ។ បើយល់
សេចក្តីនេះទៅតាមរឿង ឃើញថាប្រាសាទព្រះវិហារ
គ្រាន់តែបានជានិមិត្តរូប ១ ប៉ុណ្ណោះទេ ដូចជាដង់ហ្សិក
(Danzig) ដែលនៅក្នុងកណ្តាប់ដៃប្រទេសអាល្លឺម៉ាញ
ជំនាន់ហិត្លែរនោះដែរ ។ ត្រង់នេះកុំបីឆ្ងល់ឡើយ បើខ្មែរ
យើងហើយនៅព្រងើយកន្តើយមិនអើពើតវ៉ារឿងសៀមមក
ប្រឡាមបំពានអំណាចលើព្រះវិហារនេះទេ មុខជាទៅ
អនាគតឆាប់ៗ ប្រទេសជិតខាងគឺខ្មែរ នឹងលាវ ដែលមិន
មែនជាសមាជិកអង្គការសេ-អា-តូ នឹងបានពើបប្រទះនឹង
អំពើយង់ឃ្នងប្លែកៗទៀតរបស់សៀមមិនខាន ។

ក្រៅពីរឿងនយោបាយដូចបានពោលហើយនេះ នៅ
មានចិត្តសាស្ត្រទៅថែមលើនោះទៀត ។ ត្រង់នេះហើយ
ត្រូវឲ្យចាំថា ថៃ តែងតែមានបំណងគ្មានអាក់ ទំនុស្រូប
បញ្ចូលតាមអំណាច ជាប្រយោជន៍ខ្លួននូវអារ្យធម៌ដ៏ឆើត
របស់ខ្មែររហូតដល់ហ៊ានអះអាងថាប្រាសាទព្រះវិហារនេះគឺ

ទេវក្សត្រិយ៍ដ៏បវរទេវតាសៀមដែលរំពឹងក្រុមខាងក្រោយ
លើឡើងបង្ក្រាបខ្មែរ ហើយក្នុងសម័យបន្ទាប់មកប្រែសភាពនិន្នាការនៃខ្មែរនេះ
គោរពតាមខ្មែរនេះហើយ ដែលជាអ្នកនាំមកនូវនិស្ស័យសម្បត្តិខ្មែរ
ក្រុងទេវក្រោម ឲ្យចំណាយមរតកវប្បធម៌ខ្មែរទាំងអស់ទៀតនោះ
ក៏ដោយ ក៏នៅមានសេចក្ដីគោរពនស្សប់ណាស់ ដោយនៅក្នុង
ធំណាមួយក្រុមខ្មែរនៅមានសល់នៃកំណើតសិល្បៈនិងការដែល
ជាស្នាដៃខ្មែរនោះ ហើយនៀមខ្លួនសម្គាល់ការព្រោះគ្រឿង
បង្អួចទ្វារអស់ទាំងនោះ ក្រោមឥទ្ធិពលខ្មែរដូចជាប្រាសាទ
ពិមាយនិងផ្នែក ៗ បើបានប្រាសាទដែលមានល្អដ៏ក្រាយ
សង្គ្រប់រង់ល្អដូចជាព្រះវិហារវិញ ក៏នឹងបានអនុគ្រាន់
ទៅកើតបានថាប្រាសាទខ្មែរស្ថិតនៅក្នុងប្រទេសសៀមនោះ
កំណើតពាយតែងតែបាំងដូចប្រាសាទនានាឯទៀតដែរ ។
សារុបសេចក្ដីទៅឃើញថា សៀមចង់បានព្រះវិហារជាយ
ខាងចំណាំង ចង់ឲ្យទឹកដីនៃវត្តប៉ះលើប្រាសាទទៅកើត
ជាជាន់នឹងចង់បានផ្លូវចូលទៅកាន់ប្រាសាទនោះ ព្រោះ
ជនជាតិខ្មែរមិនដែលមាននឹកនាបាមយាត់សៀមមិនឲ្យឡើង
ចូលទៅមកកាន់ប្រាសាទនោះផងសោះ ។

# អំពីកោះកុង

មានជំណាន់រាស្ត្រថៃមណ្ឌលខេត្តត្រាត ១ នាក់មាននាមជាហ្វុងអត្តផុនពិសាល បានស្នើទៅរដ្ឋាភិបាលសៀមនៅបាងកកឲ្យទាមទារយកកោះកុង ដែលនៅក្នុងឈូងសមុទ្រជារបស់ខ្មែរនោះមកវិញ ហើយមិនញញើតនឹងអះអាងថា កោះនេះនៅក្នុងអាណាខេត្តត្រាត ហើយមានជនជាតិសៀមនៅស្នាក់អាស្រ័យ ភាគ ៨០ ក្នុង ១ រយ "៨០%" ។ ចំណែកខាងសារព័ត៌មានក៏តាំងបំផ្លើសលើនោះទៅទៀត ដោយពោលថា នៅលើកោះដែលមានដីទំហំតែ ១៩០ គ.ម. ទ្វេគុណនោះ មានជនជាតិសៀម ១ លាននាក់នៅកោះនោះ ។

ការពិតវិញកោះនេះគឺនៅក្នុងដែនសមុទ្រខ្មែរ គ្មានភស្តុតាងមករំលាយឲ្យខុសពីនេះទៅកើត ។ តែខ្មែរនៅកោះកុងតែងនិយាយភាសាពីរ តែងទទួលរាប់អានជាមិត្រនៃពួកនេសាទជាតិថៃ ហើយតែងធ្លាប់រកបិញ្ចឹមជីវិតក្នុងការពាណិជ្ជកម្មជាមួយនឹងប្រទេសថៃ ដូចជាគេតែងសំគាល់

ឃើញមានជាធម្មតាក្នុងចំណោមប្រទល់ដែនប្រទេសនោះៗ

ហេតុនេះហើយ ត្រូវតែទុកការទាមទាររបស់ដំណាងរាស្ត្រសៀម ១ នាក់នេះ ជាមធ្យោបាយពិសោធន៍១ ជាឧបាយមួយប្រយោជន៍បង្វិលជនជាតិថៃ ឲ្យមានកំហឹងទៅកាន់ជនជាតិខ្មែរ ។

x x x

ចំណែកយើងវិញ យើងដឹងបានថាឧបាយទាំងឡាយជាចក្រពត្តិនិយមរបស់ថៃ នេះ គឺមានតែអ្នកដឹកនាំថៃ ភាគតិចដែលយល់ព្រមតាមនោះ ដោយមានប្រាថ្នាឲ្យមជ្ឈដ្ឋានបរទេសចូលដៃលាយឡំជាមួយផង ហើយម៉្យាងទៀតដោយបានពឹងផ្អែកលើជនជាតិខ្មែរ១ នាក់ដែលគ្មានរុញរាទឹងពិឃាដមាតុប្រទេសខ្លួន បូជាដល់មហិច្ឆតាដ៏សាហាវរបស់ខ្លួន ឯខ្មែរនោះមិនគឺអ្នកឯណា ក្រៅពីសឺង-ង៉ុក-ថាន់នេះទេ ។

## ពីរដ្ឋមន្ត្រីទី ១ បែង ១៧៨២
## មកស៊ឹង-ង៉ុក-ថាន់ ១៩៥៧

ក្នុងពេលដែលប្រវត្តិសាស្ត្រ ប្រទេសចុះកាន់សេចក្ដីអាប់ឱន គឺក្នុងពេលកាន់ប្រែម្ដង ៗ គ្រប់តែជាតិមិនថាជាតិ

ណាជាជាតិណាទេ តែងតែមានលេចផុះឡើង នូវពួកវីរបុរសនឹងពួកក្បត់ជាតិ ហើយពួក ១ ក៏ដូចជាពួក ១ រមែងតែដើរតាមគម្រោយវីរបុរស ឬអ្នកក្បត់ជាតិពីអតីតកាលដោយមិនបានដឹងខ្លួនឬដោយស្ម័គ្រ ។

បើសិនជាត្រូវរកគ្រូដើមឲ្យ ស៊ឺង-ង៉ុក-ថាន់ វិញ ដែលប្រទេសថៃទុកជាវីរបុរស តែត្រូវទទួលឈ្មោះជាអ្នកក្បត់ជាតិក្នុងប្រទេសខ្មែរយើងនោះ យើងគួរឲ្យភ្ញាក់បាន នាកាលបើរមិលមើលទៅ ឃើញអំពើរបស់គាត់នេះមិនមានប្លែកពីអំពើមន្ត្រីខ្មែរ ១ នាក់ឈ្មោះវែន ក្នុងចុងសតវត្សរ៍ទី១៨ទេ ។

ក្នុងពេលប្រទេសកំពុងចុះក្នុងអនាធិបតេយ្យពេញទំហឹង មន្ត្រីមួយរូបនេះប្រឡោមយកអំណាចបានដោយប្រើអំពើឃោរឃៅ ៗ ក្នុងមួយជីវិតគាត់នោះ មានមួយពេលដែលវែនបានឈ្មោះជាអ្នកស្នេហាជាតិ តែថាសេចក្តីលោភលន់ឥតប្រមាណរបស់គាត់បានដឹកនាំគាត់ភ្លាម ៗ ឲ្យទៅជាអ្នកប្រឆាំង នឹងព្រះមហាក្សត្រិយ៍របស់ខ្លួន នឹង

ជនជាតិខ្លួនរហូតដល់ទៅទទួលបំរើបរទេស ដែលជាខ្មាំងទៅវិញ ។

ព្រះចៅប្រទេសសៀមទ្រង់បានប្រទានដល់ឈ្មោះបែន ជារដ្ឋមន្ត្រីទី១ខ្មែរនូវគោរម្យងារជា "ចៅពញាអភ័យធិបេស្រ៍វិសេសសង្គ្រាមរាម" ជាគោរម្យងាររបស់ចៅហ្វាយខេត្តបាត់ដំបង ។ តទៅខាងមុខនេះ យើងអាចនឹងបានដឹងអំពីបំណងនៃការប្រែប្រួលក្នុងគោរម្យងារ និងក្នុងគំនិតរបស់មន្ត្រីនេះ ។

"បែន ដែលមានមុខងារជាចៅហ្វាយខេត្ត ឬជាឧបរាជក្នុងខេត្តបាត់ដំបងនេះ បានទទួលធ្វើជាមេកងទ័ពសៀម ត្រូវទទួលបេសកកម្មនាំព្រះមហាក្សត្រខ្មែរឲ្យបានវិលមកគង់លើព្រះរាជបល្ល័ង្កវិញ និងចាត់ចែងឲ្យប្រទេសបានចូលកាន់សេចក្ដីរៀបរយឡើងវិញ" ។

លុះបានបំពេញបេសកកម្មនេះហើយបែនត្រូវវិលត្រឡប់ទៅកាន់បាត់ដំបងវិញជាមួយនឹងកងទ័ពសៀម ព្រោះគាត់ត្រូវទទួលធ្វើជាចៅហ្វាយខេត្ត ។ នោះដោយមានលក្ខខណ្ឌថា:

ត្រូវឲ្យគាត់ឡើងស្ដេចសៀមផ្ទាល់ ហើយទទួលបញ្ជាតែពីស្ដេចនេះ ឯខេត្តសៀមរាបក៏ត្រូវមានសភាពដូចខេត្តបាត់ដំបងដែរ រីឯចៅហ្វាយខេត្តពិសេសនៃខេត្តនេះត្រូវនៅក្នុងឱវាទផ្ទាល់ចៅហ្វាយខេត្តបាត់ដំបង ។

លោកម៉ូរ៉ា ដែលសរសេររឿងនេះក៏បានបញ្ចប់សេចក្ដីដូចតទៅ :

"អ្នកនយោបាយខ្មែរទាំងឡាយ នៃប្រទេសខ្មែរបានដឹងច្បាស់ថា របៀបដែលបានចែងមកហើយនេះមិនគឺអ្វីក្រៅពីព្រះរាជតម្រិះរបស់ស្ដេចសៀម និងស្នាដៃរបស់ជនអប្រិយ៍គឺថៃនេះទេ ក្នុងសាវតារគេបានស្រង់អំពើល្មោភហេសស្បូបាយ (Intrigues) នឹងបទទុក្រិដ្ឋទាំងឡាយរបស់មន្ត្រីនេះបានទាំងអស់ អំពើអកុសលទាំងនេះហើយដែលនាំឲ្យអាប់កិត្តិយសដល់ខ្លួនគាត់ផង ដល់ពួកសៀមផងជាទីអវសាននៃមុខក្រសួងគាត់" ។

ចំណែកខាង ស៊ីង-ង៉ុក-ថាន់ គាត់ក៏ជាអ្នកស្នេហាជាតិមួយពិតប្រាកដដែរក្នុងរវាងកំណត់ឆ្នាំ ១៩៤០-១៩៤៥ ។

អំពើដែលគាត់បានប្រព្រឹត្ត ក្នុងចំណោមសមណៈក្នុងឆ្នាំ ១៩៤២នោះ នាំឲ្យមានគេរាប់អានគាត់ច្រើនគ្នាៗតែក្រោយដែលបារាំងសែស បានធ្វើប្រតិកម្មតបតនឹងគាត់វិញនោះ គាត់ក៏រត់ចោលប្រទេស ហើយទៅលាក់ខ្លួនពួនអាត្មានៅស្ថានទូតជប៉ុននាក្រុងបាងកកទៅ ៗ មកទល់នឹងឆ្នាំ ១៩៤៥ ហើយខ្លួនគាត់នេះបានទៅជាវត្ថុ១ នៅក្នុងកណ្ដាប់ដៃអាណានិគមជប៉ុនៗ បាននាំគាត់មកបង្គំថ្វាយព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ឲ្យទទួលយកធ្វើជារដ្ឋមន្ត្រីទី ១ ក្នុងខែសីហា ឆ្នាំ ១៩៤៥ ៗ បានដូច្នោះហើយ ក៏គាត់លែងញញើតនឹងធ្វើអាការៈបៀតបៀនដល់ព្រះបរមមហាក្សត្រិយ៍របស់គាត់ ព្រោះគាត់យល់ថាព្រះបេស្កាព្រះរាជាក្នុងពេលកលិយុគនោះជាការ១ដែលសន្មតថាឥតប្រយោជន៍ៗ

ក្នុងខែតុលា ១៩៤៦ កងទ័ពក្រៅ (Corps expéditionnaire) ក៏ចាប់ខ្លួនគាត់បានហើយយកទៅជំនុំជំរះគាត់ទោសឲ្យធ្វើការជាទម្ងន់ចំនួន ២០ ឆ្នាំ ពីរឿងក្បត់ ទោស

នេះគាត់បានទៅទទួលនៅឯប្រទេសបារាំង ក្នុងការបន្ទុះ-បន្ទុយជាច្រើន ។

ចំណែកព្រះបាទសម្តេច ព្រះ នរោត្តម-សីហនុ វិញ ព្រះអង្គទ្រង់ព្រះមេត្តាប្រោសក្តេចសេចក្តីប្រមាថដែលជនមួយរូបនេះបានប្រព្រឹត្តរំលោភលើព្រះអង្គ ក៏ព្រះអង្គស៊ីឲ្យបានលើកទោសចោល ហើយឲ្យវិលចូលត្រឡប់មកកាន់មាតុប្រទេសវិញ ក្នុងឆ្នាំ ១៩៥១ ។

ប៉ុន្តែមកដល់ប្រទេសវិញភ្លាម ស៊ឺង-ង៉ុក-ថាន់ ក៏ចាប់ប្រឆាំងនឹងព្រះចេស្តាព្រះមហាក្សត្រិយ៍គាត់ភ្លាមដែរ ។ ចាំងនេះគឺមកពីសេចក្តីឡើតមិនសមហេតុផលពីសេចក្តីលោភលន់ឥតមានទីអវសានរបស់គាត់ នាំឲ្យគាត់ទទួលយល់ព្រមផងមិនបាន ពីការដែលសម្តេចព្រះ នរោត្តម-សីហនុ ទ្រង់បានប្រារព្ធការបានផល តាមព្រះរាជបំណងគ្រង់ណាដែលចំណែកគាត់ ៗ ធ្វើមិនកើតនោះ គឺអំពីឯករាជ្យជាតិបរិបូណ៌ ដែលព្រះអង្គទ្រង់ស្វែងរកមកបូជាប្រទេសបាន ។ ក្រោយដែល កងកម្លាំងគាត់បានបរាជ័យបាក់បែកអស់ទៅ

នោះ សឺង-ង៉ុក-ថាន់ បានរត់ទៅជ្រកនៅប្រទេសថៃ រួចក៏តាំងបវារណាខ្លួនបំរើរដ្ឋាភិបាលថៃ ផ្ដើមទាក់ទងនឹងពួកយៀកមិញ រួមទាំងពួកអាមេរិកាំង សារឫតែដើរពឹងមហាអំណាចបរទេសណា ដែលគេហ៊ានធានាអះអាងនឹងជួយខ្លួនឲ្យបានមានអំណាចឡើងវិញកើត ព្រោះគាត់រស់នៅបាន ក៏ដោយសារតែគាត់ប្រាថ្នាអំណាចនេះដែរ ។ រួចពីអ្នកស្នេហាជាតិនាឆ្នាំ ១៩៤២ មក សឺង-ង៉ុក-ថាន់ប្រែក្លាយទៅជាអ្នកក្បត់ជាតិទៅវិញ ទទួលយកកម្រៃ ៦.០០០ បាត ពីឧត្តមសេនីយ៍ស្រីយានន្ទ ដែលមានល្បីឈ្មោះខាងខូច ហើយដែលត្រូវគេបណ្ដេញចេញពីប្រទេស ក្នុងឱកាសរដ្ឋប្រហារពីថ្ងៃ ១៦ កញ្ញា ឆ្នាំ ១៩៥៧ ។ សឺង-ង៉ុក-ថាន់នេះ គឺព្រមទទួលយូរប៉ែបណាក៏បាន ដូច្នេះហើយបានជាគាត់មិនមានរុញរា នឹងស្នើសុំដល់រដ្ឋាភិបាលយៀកណាមខាងត្បូងឲ្យអនុញ្ញាតឲ្យគាត់មកបំបះពួកខ្មែរកម្ពុជាក្រោម ឲ្យបះប្រឆាំងនឹងមាតុភូមិខ្លួន ។ គេបានឲ្យការណ៍ថាគាត់តែងទៅមកកាន់ស្រុកកោះកុងឬក្នុងដងរែក មិនដឹងជាទៅធ្វើការស្ងាត់

កំបាំងយ៉ាងណាឲ្យសៀមជាម្ចាស់គាត់សោះ នេះជាការគាប់ជូនគួរឲ្យសង្ស័យពេក ។

កាល ១០ ឆ្នាំមុននេះ សឺង-ង៉ុក-ថាន់ នៅមានប្រជារាស្ត្រអ្នកបេះដូងច្រើនគេស្រឡាញ់រាប់អានគាត់ ។ ថ្ងៃនេះពលរដ្ឋខ្មែរមួយនាក់ៗ ដែលមានសតិសម្បជញ្ញៈដល់ការលើកដំកើងជាតិផង ដល់គ្រោះថ្នាក់ដែលកំពុងកំញើញគម្រាមប្រទេសខ្លួនផងនោះ អានតែពីសេចក្ដីមើលងាយទ្ទើមរអើមដល់បុរស ១ នាក់នេះ ដែលបានលក់ខ្លួនទៅឲ្យបរទេសជាស្រេចដាច់ខាតទៅហើយនេះ ។

•

•   •

ទីបញ្ចប់ ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិដែលនៅមូលត្រកូលក្នុងប្រទេសជាមួយគ្នាក្ដី ដែលខ្ចាត់ខ្ចាត់ទៅនៅដោយប្រទេសដទៃក្ដី ទោះបីជាទៅស្ថិតនៅដោយចេតនាក្ដី ដោយសារតែភាពប្រទេសបង្ខំឲ្យទៅដូចជានាវាត្រូវព្យុះសង្ឃរាអណ្ដែតទៅគៀងជាប់នៅត្រើយឬកោះណាក្ដី មេត្តាមើលហើយពិចារណានូវភាពប្រវត្តិសាស្ត្រប្រទេសយើងនេះឲ្យបានសព្វគ្រប់ ដើម្បីបានដាស់តឿនសតិបញ្ញាកុំឲ្យធ្លាក់

ចុះទៅកាន់អំពើអកុសលឯណាមួយ ដែលជាហេតុនាំឲ្យប្រទេសចុះអាប់ឱនបែកបាក់ដោយសារតែសេចក្ដីលោភលន់ផុតពន់ប្រមាណដូចមានឧទាហរណ៍ក្នុងរឿងដែលស្រង់ជូនជាបខាងលើនេះស្រាប់ ។

ព្រះបាទសម្ដេចព្រះ នរោត្ដម-សីហនុ ព្រះអ-មហាក្សត្រិយ៍យើង ព្រះអង្គបានបំពេញព្រះរាជបេសកកម្មទាមទារយកឯករាជ្យជាតិពិត មកបូជាប្រទេសបាន ហើយក៏ព្រះអង្គបានចុះពីព្រះរាជបល្ល័ង្ក មកស្ថិតនៅជិតស្និទ្ធជាមួយនឹងពលរដ្ឋរបស់ព្រះអង្គ ដើម្បីស្វែងរកសេចក្ដីសុខ-ចំរើនជូនរាស្ដ្ររបស់ព្រះអង្គជាមួយនឹងពលរដ្ឋព្រះអង្គ នឹងបង្រួបបង្រួមជាតិកុំឲ្យបែកបាក់ដោយបានបង្កើតចលនាសង្គមរាស្ដ្រនិយម ។ ទាំងនេះមិនគឺអ្វីក្រៅពីព្រះរាជបំណងដ៏វិសេសលើសលប់ក្នុងការរក្សាមាតុប្រទេសឲ្យគង់វង់ ហើយនឹងរកមធ្យោបាយតម្កើងជីវភាពប្រទេស ឲ្យបានចូលកាន់អារ្យធម៌ វឌ្ឍនភាពឲ្យសមតាមកាលសម័យនោះទេ ។ ក្នុងប្រវត្តិសាស្ត្រនៃប្រទេសនានាក្នុងពិភពលោកក្ដី តើមាន

ក្សត្រិយ៍ប៉ុន្មានអង្គ ដែលបានបំពេញព្រះរាជកិច្ចបូជាមាតុប្រទេស ៖ហើយត្រឡប់ជាដាក់រាជ្យទៅជាក្សត្រិយ៍សាមញ្ញនោះ ពិតមែនហើយជាខេមរជាតិបានថ្វាយព្រះនាមជាព្រះមហាវីរក្សត្រិយ៍ផង ជាព្រះបិតាឯករាជ្យជាតិផង ។

ខ្ញុំសូមបងប្អូនរួមជាតិ លើកយកព្រះអង្គនេះជាតួយ៉ាងជាគំរូក្នុងករណីយកិច្ចចំពោះជាតិសាសនា នឹងព្រះមហា-ក្សត្រិយ៍ ដែលពលរដ្ឋ ១ នាក់ៗត្រូវបំពេញចំពោះជាតិ-សាសនា-ព្រះមហាក្សត្រិយ៍ពេលនេះៗ សាកលលោកកំពុងរំកើបរំជួយដោយកម្លាំងលោភៈទោសៈមោហៈ សូម្បីតែប្រទេសយើងតូច១នេះ ដែលកាន់អព្យាក្រិតព្រោះប្រាថ្នាតែសេចក្តីសុខក៏តើបប្រទះនឹងអំពើអកុសលនេះដែរ ហើយក្នុងពេលដែលខ្ញុំកំពុងតែរៀបរៀងសេចក្តីនេះទៀត ក៏វិទ្យុជាតិបានផ្សាយនូវសេចក្តីប្រកាស ឯកឧត្តម ស៊ឹម-វ៉ា នាយករដ្ឋមន្ត្រីជូនដំណឹងដល់ជាតិ ពីការរំលោភដ៏សាហាវរបស់កងកម្លាំងសឹកវៀតណាមខាងត្បូង ដែលលើកគ្នាមកព័ទ្ធឡោមយកឃុំខ្មែរមួយ "ប៉ាកញ៉ៃ" ក្នុងខែត្រស្ទឹង

តែង ដែលនៅចម្ងាយ ៧ គីឡូម៉ែត្រពីប្រទល់ដែនយៀក

ណាម ។ ចំណែកខ្ញុំដែលជាពលរដ្ឋខ្មែរមួយរូបមានកត្

សំណាងពិសេស បានធ្វើជាសហការី ព្រះបាទសម្ដេចព្រះ

នរោត្តម-សីហនុ ព្រះបិតាឯកភាពជាតិខ្មែរ តាំងពី

បរមកាលរហូតដល់បច្ចុប្បន្នកាលនេះ ហើយបានស្គាល់

ច្បាស់នូវព្រះរាជហឫទ័យនៃព្រះអង្គ ចំពោះជាតិនិងរាស្ត្រ

ព្រះអង្គនោះ ខ្ញុំមានករណីយកិច្ចនឹងរៀបរៀងសេចក្ដីនេះ

ជូនជនរួមជាតិជាទីស្នេហា ដើម្បីជាទីតបស្នងសងព្រះ

គេជះព្រះគុណចំពោះព្រះមហាវីរក្សត្រិយ៍អង្គនេះដែលយើង

ត្រូវរាប់បញ្ចូលទៅក្នុងវង្សក្សត្រិយ៍ដែលបានកសាងប្រាសាទ

អង្គរនិងលើកស្ទួយតំកើងប្រទេសជាតិ ឲ្យបានចូលកាន់

កុំពូលអារ្យធម៌ដែលជាទីស្ញប់ស្ញែងនៃពិភពលោក រហូតមក

ដល់សម័យនេះ ។

សេចក្តីចំរើនរុងរឿង - សេចក្តីចំរើនដល់ជាតិ - មាតុប្រទេស ពុំអាចស្ថិតលើអ្វីកើតបានក្រៅពីលើសេចក្តីសាមគ្គីភាព នៃពលរដ្ឋជុំវិញព្រះរាជបល្ល័ង្កនោះទេ ។ នេះហើយជាប្រស្នាសុភមង្គល ។

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ....................
រាជបណ្ឌិត្យសភាកម្ពុជា